# របៀបការពារសុខភាពទារក និងសុខភាពរបស់អ្នកផ្ទាល់ ប្រសិនបើអ្នកមានរោគរលាកថ្លើមប្រភេទ B និងកំពុងមានផ្ទៃពោះ

**រោគរលាកថ្លើមប្រភេទ B គឺជាជំងឺធ្ងន់ធ្ងរដែលទារករបស់អ្នកអាចផ្ទុកអស់មួយជីវិត។ ប្រសិនបើអ្នកមានផ្ទៃពោះ និងមានរោគរលាកថ្លើមប្រភេទ B វីរុសនេះអាចចម្លងទៅទារកទើបនឹងកើតរបស់អ្នកតាមការប៉ះពាល់ជាមួយឈាមរបស់អ្នកនៅពេលកើត។ ដើម្បីបង្ការកុំឱ្យឆ្លងរោគទៅទារក និងជួយឱ្យអ្នកបន្តមានសុខភាពល្អ សូមទៅជួបអ្នកផ្តល់សេវាថែទាំសុខភាពឱ្យបានទាន់ពេល ក្នុងអំឡុងពេលមានផ្ទៃពោះ និងពិគ្រោះជាមួយពួកគេអំពីរោគរលាកថ្លើមប្រភេទ B។**



**សូមប្រើតារាងនេះដើម្បីតាមដានការថែទាំរបស់អ្នកនិងការថែទាំទារករបស់អ្នកក្នុងអំឡុងនិងក្រោយពេលមានផ្ទៃពោះ!**

## សម្រាប់ម្តាយ

### អំឡុងពេលមានផ្ទៃពោះ

- ✓ សូមទៅជួបអ្នកផ្តល់សេវាថែទាំសុខភាពដើម្បីទទួលការថែទាំសម្រាប់រោគរលាកថ្លើមប្រភេទBឱ្យបានទាន់ពេលក្នុងពេលមានផ្ទៃពោះ ដើម្បីពិនិត្យមើលកម្រិតរោគរលាកថ្លើមប្រភេទ B និងមុខងារថ្លើមរបស់អ្នក។
  - អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចចេញវេជ្ជបញ្ជាសម្រាប់រោគរលាកថ្លើមប្រភេទ B ប្រសិនបើចាំបាច់។

### នៅពេលកើត

- ✓ សូមប្រាកដថាបុគ្គលិកមន្ទីរពេទ្យដឹងថាអ្នកមានរោគរលាកថ្លើមប្រភេទ B។
- ✓ សូមប្រាកដថាអ្នកផ្តល់សេវាថែទាំសុខភាពដែលនឹងថែទាំទារករបស់អ្នកដឹងថា អ្នកមានរោគរលាកថ្លើមប្រភេទ B។

### ក្រោយពេលកើត និងបន្តបន្ទាប់

- ✓ ពេលអាយុ1-2ខែ សូមបន្តទៅជួបអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកដើម្បីទទួលការថែទាំសម្រាប់រោគរលាកថ្លើមប្រភេទ B។
  - ចំណុចនេះសំខាន់ខ្លាំងណាស់ ប្រសិនបើអ្នកបានចាប់ផ្តើមការព្យាបាលអំឡុងពេលមានផ្ទៃពោះ។
- ✓ សូមបន្តទៅជួបអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ដើម្បីតាមដានរោគរលាកថ្លើមប្រភេទ B យ៉ាងហោចណាស់រៀងរាល់ 6 ខែម្តង។

**ត្រូវប្រាកដថាដៃគូរបស់អ្នក និងអ្នកដែលរស់នៅជាមួយអ្នក ធ្វើតេស្ត និងចាក់វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B អំឡុងពេលអ្នកមានផ្ទៃពោះ។**

## សម្រាប់ទារក

### នៅពេលកើត

ទារកត្រូវតែចាក់ថ្នាំ 2 ដងក្នុងចន្លោះ 12 ម៉ោងបន្ទាប់ពីកើតមក ដើម្បីការពារកុំឱ្យឆ្លងរោគ៖

- ✓ ក្លូប៊ុយលីនបង្កើនភាពស៊ាំប្រឆាំងនឹងរោគរលាកថ្លើមប្រភេទ B (HBIG) មួយម្ជុល
- ✓ វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B លើកទី 1

### 1-2 ខែ

- ✓ ទារករបស់អ្នកដល់ពេលចាក់វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B លើកទី 2។

### 6 ខែ

- ✓ ទារករបស់អ្នកដល់ពេលចាក់វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B លើកទី 3។

### 9-12 ខែ

- ✓ ទារករបស់អ្នកត្រូវធ្វើតេស្តឈាម ដើម្បីពិនិត្យស្ថានភាពរោគរលាកថ្លើមប្រភេទ B និងវាយតម្លៃកម្រិតការពាររបស់ទារក។

### ការបំបៅដោះកូន

- ✓ សូមពិគ្រោះជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអំពីជំនួយផ្នែកបំបៅដោះកូន និងរបៀបបង្ការ ឬគ្រប់គ្រងក្បាលដោះដែលហូរឈាមឬប្រេះ ដើម្បីកាត់បន្ថយការប៉ះពាល់របស់ទារកជាមួយឈាមរបស់អ្នក។
- ✓ ប្រសិនបើទារកទើបនឹងកើតបានចាក់វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B និងក្លូប៊ុយលីនបង្កើនភាពស៊ាំប្រឆាំងនឹងរោគរលាកថ្លើមប្រភេទ B នៅពេលសម្រាល នោះហានិភ័យនៃការចម្លងរោគរលាកថ្លើមប្រភេទ B ពីម្តាយទៅទារកតាមរយៈការបំបៅដោះកូនគឺទាបណាស់។ បន្ទាប់ពីទារកចាក់ថ្នាំទាំងនេះហើយ អ្នកអាចបំបៅដោះកូនដោយសុវត្ថិភាព។

HepBHub
doh.wa.gov/hepbhub

Washington State Department of Health

DOH 420-441 October 2022 Khmer
ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមហៅទូរសព្ទមកលេខ 1-800-525-0127។ អតិថិជនដែលពិការត្រចៀកឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ civil.rights@doh.wa.gov។ បានកែសម្រួលមកពី North East Medical Services, www.nems.org។.